គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia
និយ័តករបរធនបាលកិច្ច
Trust Regulator
លេខ ៦១ ចេញផ្សាយថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២
No. 61 Released on November 21, 2022

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

## ការគ្រប់គ្រងទំនាស់ផលប្រយោជន៍របស់បរធនបាលកិច្ច

## Management of Conflicts of Interest in Trust Sector




https://media.istockphoto.com/photos/trust-picture-id510782256?k=20&m=510782256&s=170667a&w=0&h=s5kvLARRptfwtMvLOJ27CI9YSMZhU6f7yJnUDiGUBy0=

យោងតាមច្បាប់ស្តីពី "បរធនបាលកិច្ច" (២០១៩), បទប្បញ្ញត្តិពាក់ព័ន្ធ និងប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតតាមប្រកាសនេះ ត្រូវកំណត់ឱ្យបានច្បាស់ជាលាយលក្ខណ៍អក្សរនូវគោលនយោបាយស្តីពីការបង្ការ និងការគ្រប់គ្រងទំនាស់ផលប្រយោជន៍។ គោលនយោបាយនេះ ត្រូវទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការ ដែលចាត់តាំងដោយក្រុមប្រឹក្សាភិបាល និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅក្នុងក្រុមហ៊ុនបរធនបាល។

ក្រុមហ៊ុនបរធនបាលត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយនេះរបស់អភិបាល នាយកប្រតិបត្តិប្រធានផ្នែក និងបុគ្គលិកក្នុងតំណែងគ្រប់គ្រងទាំងអស់។

ទំនាស់ផលប្រយោជន៍នេះសំដៅដល់ទំនាស់ផលប្រយោជន៍ ដូចខាងក្រោម÷

**១.** រវាងបរធនបាលទាយកទាំងឡាយ ដែលបានបង្កើតបរធនបាលកិច្ចនៅក្រោមការគ្រប់គ្រង និងចាត់ចែងដោយក្រុមហ៊ុនបរធនបាល និងបុគ្គលពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច និងប្រតិបត្តិការរបស់ក្រុមហ៊ុនបរធនបាល។

**២.** រវាងបរធនបាលកិច្ច និងបរធនបាលកិច្ចដែលខ្លួនគ្រប់គ្រង។

**៣.** រវាងអត្ថគាហកៈ និងអត្ថគាហកៈ។

បរធនបាលរូបវន្តបុគ្គលឯករាជ្យដែលទទួលបានអាជ្ញាបណ្ណតាមប្រកាសនេះ ត្រូវកំណត់ឱ្យបានច្បាស់ជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងកថាខណ្ឌទី៣ នៃប្រការនេះ។

ក្នុងករណីដែលបរធនបាលមួយប្រកបអាជីវកម្មផ្សេងពីប្រតិបត្តិការបរធនបាលកិច្ច ដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពី **ន.ប.ធ.** បរធនបាលនៃបរធនកិច្ចនីមួយៗ ត្រូវមានទីតាំងអាជីវកម្មបរិក្ខារ ប្រព័ន្ធព័ត៌មានវិទ្យា ធនធានមនុស្សដាច់ដោយឡែកពីគ្នារវាងអាជីវកម្មនីមួយៗ នឹងត្រូវមានរបាំងព័ត៌មាន (Chinese Wall) សមស្រប។

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

According to the Law on Trust (2019), relevant provisions and Prakas No. 003 dated January 26, 2022, on " Rules on the Management, Organization, and the Functioning of Trust ", the licensed and/or permitted trust company according to this Prakas shall clearly define in writing the policy on the prevention and management of conflicts of interest. This policy shall be approved by the Board of Directors, or a committee appointed by the Board of Directors and shall be widely disseminated within the trust company.

The trust company shall promote and monitor the implementation of this policy by the director, CEOs, Heads of Departments, and all management staff.

This conflict of interest refers to the following conflicts of interest:

1. Between the trustors who have established trust under the control and management of the trust company and the persons involved in the operations of trust and the operations of the trust company.

2. Between trust and the trust under its control.

3. Between the beneficiary and the beneficiary.

The independent physical trustee who is licensed in accordance with this Prakas shall be clearly defined in writing as stated in the third paragraph of this article.

In the event that a trustee conducts a business other than a trust operation that has received a license and / or permission from the trust regulator, each trustee must have a separate business location, IT equipment, human resources, between each business will have an appropriate Chinese Wall.

អត្ថបទ÷ កញ្ញា ភាន់ វីរ៉ាលីន | Article: PHORN Viralynn

ឯកសារយោង | References:

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- អនុក្រឹត្យស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ (២០១៣)
- ប្រកាសស្តីពីវិធានគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.